ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ.......................................................

*ថ្ងៃព្រហស្បតិ៍ ១៥រោច ខែផល្គុន ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២*
*រាជធានីភ្នំពេញ ថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៩*

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពី ការតភ្ជាប់ប្រព័ន្ធទូទាត់សងប្រាក់ក្នុងអាស៊ាន៖ កម្ពុជា និងថៃ

កិច្ចប្រជុំថ្នាក់ទេសាភិបាលធនាគារកណ្តាលអាស៊ាន
ថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៩ ខេត្តឈាងរ៉ៃ ប្រទេសថៃ

ធនាគារជាតិនៃកម្ពុជា និងធនាគារកណ្តាលថៃ បានបន្តពង្រឹងចំណងមិត្តភាព ក្នុងផ្នែកទូទាត់ និងការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុ។

កាលពីខែកុម្ភៈ ឆ្នាំ២០១៩កន្លងទៅ ឯកឧត្តម ជា ចាន់តូ ទេសាភិបាល ធនាគារជាតិនៃកម្ពុជា និងឯកឧត្តម Veerathai Santiprabhob ទេសាភិបាល ធនាគារកណ្តាលថៃ បានចុះហត្ថលេខាលើអនុស្សរណៈយោគយល់ ស្តីពី កិច្ចសហប្រតិបត្តិការក្នុងផ្នែកនវានុវត្តភាពហិរញ្ញវត្ថុនិងប្រព័ន្ធទូទាត់ នៅរាជធានីភ្នំពេញ។ អនុស្សរណៈយោគយល់នេះ ត្រូវបានធ្វើឡើងក្នុងគោលបំណង ធ្វើឱ្យការទូទាត់សងប្រាក់ក្នុងស្រុកនិងឆ្លងដែន កាន់តែមានប្រសិទ្ធភាព ចំណាយទាបសមរម្យ និងមានសុវត្ថិភាព ព្រមទាំងគាំទ្រដល់ការប្រើប្រាស់រូបិយវត្ថុក្នុងស្រុក។

នាថ្ងៃនេះ នៅខេត្តឈាងរ៉ៃ ទេសាភិបាលនៃធនាគារកណ្តាលទាំងពីរបានអញ្ជើញចូលរួមជាអធិបតីក្នុងឱកាសនៃការបង្ហាញពី «អន្តរប្រតិបត្តិការនៃការទូទាត់តាមប្រព័ន្ធ QR (Interoperable QR Payment)» រវាង Siam Commercial Bank (SCB) របស់ប្រទេសថៃ និងសាខារបស់ខ្លួននៅកម្ពុជា ដើម្បីបន្តការសហការដ៏រឹងមាំក្នុងការតភ្ជាប់ប្រព័ន្ធទូទាត់សងប្រាក់រវាងប្រទេសទាំងពីរ។ អន្តរប្រតិបត្តិ-ការនៃការទូទាត់សងប្រាក់តាមប្រព័ន្ធ QR នេះត្រូវបានធ្វើឡើងតាមស្តង់ដារ EMV ដែលនឹងអាចសម្រួលដល់ការទូទាត់រាយឆ្លងដែនរវាងបុគ្គល និងពាណិជ្ជករក្នុងប្រទេសទាំងពីរ។ ជាមួយនឹងសេវាកម្មនេះ ភ្ញៀវទេសចរថៃនឹងអាចប្រើប្រាស់កម្មវិធីធនាគារចល័តក្នុងទូរសព្ទដៃ ដើម្បីស្កេន QR code និងធ្វើការទូទាត់សងប្រាក់ទៅកាន់ពាណិជ្ជករកម្ពុជា។ ខណៈដែលការបង្ហាញនៅថ្ងៃនេះជាការបង្ហាញសាកល្បងអំពីការទូទាត់តាមរយៈការផ្ទេរប្រាក់ក្នុងប្រព័ន្ធធនាគារ ប្រទេសទាំងពីរនឹងបន្តធ្វើការជាមួយគ្នាក្នុងការពង្រីកបណ្តាញទូទាត់សងប្រាក់ និងធ្វើឱ្យការទូទាត់ឆ្លងដែនតាមប្រព័ន្ធ QR អាចធ្វើឡើងដោយធនាគារភាគច្រើននៅប្រទេសកម្ពុជានិងថៃបានយ៉ាងរលូន ជាមួយនឹងការអភិវឌ្ឍនៃហេដ្ឋារចនាសម្ព័ន្ធអន្តរប្រតិបត្តិការនេះ។

ប្រអប់សំបុត្រលេខ ២៥, ផ្លូវលេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

ឯកឧត្តម ជា ចាន់តូ ទេសាភិបាល ធនាគារជាតិនៃកម្ពុជា បានមានប្រសាសន៍ថា «ការបង្កើតនូវប្រព័ន្ធទូទាត់តាមរយៈ QR code គឺមានសារៈសំខាន់ណាស់សម្រាប់ប្រទេសទាំងពីរ ដើម្បីសម្រួលដល់ការទូទាត់សងប្រាក់ឆ្លងដែន និងកាត់បន្ថយហានិភ័យនិងការចំណាយក្នុងការទូទាត់ ព្រមទាំងពង្រឹងប្រសិទ្ធភាពការទូទាត់រវាងប្រទេសទាំងពីរ។»

ឯកឧត្តម Veerathai Santiprabhob ទេសាភិបាល ធនាគារកណ្តាលថៃ បានមានប្រសាសន៍ថា «ខ្ញុំមានសេចក្តីសោមនស្សរីករាយដែលបានពិនិត្យឃើញពីវឌ្ឍនភាពនៃនវានុវត្តភាពហិរញ្ញវត្ថុនៅក្នុងសេវាទូទាត់ឆ្លងដែនរវាងកម្ពុជានិងថៃ ជាពិសេសផ្តោតលើការបង្កើតហេដ្ឋារចនាសម្ព័ន្ធហិរញ្ញវត្ថុនៃអន្តរប្រតិបត្តិការ។ ការវិវត្តនេះមានសារៈសំខាន់ណាស់ ដោយសារកម្ពុជាជាទិសដៅទេសចរណ៍ដ៏ពេញនិយមសម្រាប់ភ្ញៀវទេសចរថៃ និងការណ៍ដែលអាចប្រើប្រាស់កម្មវិធីធនាគារចល័តតាមទូរសព្ទដៃក្នុងការទូទាត់ជាមួយពាណិជ្ជករកម្ពុជា នឹងអាចពង្រឹងដល់ប្រសិទ្ធភាពនៃការទូទាត់ឆ្លងដែន ក៏ដូចជាជំរុញដល់ការប្រើប្រាស់ការទូទាត់តាមអេឡិចត្រូនិករវាងប្រជាជននៃប្រទេសទាំងពីរ។ លើសពីនេះ ការបង្ហាញនាថ្ងៃនេះគឺគ្រាន់តែជាជំហានដំបូងនៃអន្តរប្រតិបត្តិការនៃការទូទាត់សងប្រាក់តាមប្រព័ន្ធ QR រវាងប្រទេសទាំងពីរប៉ុណ្ណោះ។ ដើម្បីបន្តឈានទៅមុខទៀត ការអនុវត្តកាន់តែទូលំទូលាយនូវយន្តការអន្តរប្រតិបត្តិការនៃការទូទាត់សងប្រាក់តាមប្រព័ន្ធ QR នឹងអនុញ្ញាតឱ្យការទូទាត់សងប្រាក់ឆ្លងដែនតាមប្រព័ន្ធ QR អាចធ្វើឡើងបានដោយធនាគារភាគច្រើននៃប្រទេសថៃនិងកម្ពុជា។»

**ទំនាក់ទំនង ៖**
ផ្នែកទំនាក់ទំនង, ធនាគារជាតិនៃកម្ពុជា
ទូរសព្ទ ៖ (៨៥៥) ២៣ ៩៩០ ១៩៦
អ៊ីម៉ែល ៖ nbccommunication@nbc.org.kh